# II- ផ្នែករាជការគណៈរដ្ឋមន្ត្រី

## អនុក្រឹត្យ

*រាជធានីភ្នំពេញ, ថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ១៩៩៤*

### អនុក្រឹត្យលេខ ៤២ អនក្រ

### ស្តីពីការបញ្ចប់ភារកិច្ចរបស់ទីប្រឹក្សាអមនាយករដ្ឋមន្ត្រី នៃ រាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកកិច្ចការពារជាតិ

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញក្រឹត្យស្តីពីការតែងតាំងឯកឧត្តម ឧត្តមសេនីយ៍ **សក់ ស៊ុតសាខន** ជាទីប្រឹក្សាអមសហប្រធាននៃរដ្ឋាភិបាលជាតិបណ្តោះអាសន្នកម្ពុជាទទួលបន្ទុកកិច្ចការការពារជាតិ ចុះថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ១៩៩៣
- បានឃើញសេចក្តីសំរេចលេខ ២៨ សសរ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីមុខងារ និង ភារកិច្ច របស់ឯកឧត្តម ឧត្តមសេនីយ៍ **សក់ ស៊ុតសាខន**
- បានឃើញអនុក្រឹត្យលេខ ៧៣ អនក្រ ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងបុគ្គលិកជំនួយការរបស់ឯកឧត្តម ឧត្តមសេនីយ៍ **សក់ ស៊ុតសាខន**
- បានឃើញអនុក្រឹត្យលេខ ២៩ អនក្រ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងមន្ត្រីជំនួយការរបស់ឯកឧត្តម ឧត្តមសេនីយ៍ **សក់ ស៊ុតសាខន**
- យោងតាមសភាពការណ៍ជាក់ស្តែងក្នុងបច្ចុប្បន្ន

### សំរេច

**មាត្រា ១ :** បញ្ចប់ភារកិច្ចរបស់ឯកឧត្តម **សក់ ស៊ុតសាខន** អតីតទីប្រឹក្សាអមនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកកិច្ចការការពារជាតិ ។

**មាត្រា ២ :** ប្រគល់ជូនទៅក្រសួងការពារជាតិវិញ នូវ ឧបករណ៍ និង បុគ្គលិកយោធាទាំងអស់ដែលបំរើការងារក្នុងខុទ្ទកាល័យនេះ ។

**មាត្រា ៣ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិសហរដ្ឋ មន្ត្រីក្រសួងមហាផ្ទៃ នាយឧត្តមសេនាធិការ នៃកងយោធពលខេមរភូមិន្ទ បណ្តាក្រសួងដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តតាមអនុក្រឹត្យនេះដែលចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ៕

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

ព្រះហស្តលេខា និង ត្រា ហត្ថលេខា និង ត្រា

**នរោត្តម រណឫទ្ធិ** **ហ៊ុន សែន**

***

*រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ១៩៩៤*

## អនុក្រឹត្យលេខ ៤៣ អនក្រ

## ស្តីពីសណ្តាប់ធ្នាប់សាធារណៈនៅរាជធានីភ្នំពេញ

## និង ខេត្ត ក្រុង

រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំរេច

**មាត្រា ១ :** ការរៀបចំសណ្តាប់ធ្នាប់សាធារណៈ សុវត្ថិភាពសាធារណៈ ភាពស្ងប់ស្ងាត់អនាម័យ និង ភាពនាំអោយមានសុខភាពល្អ នៅរាជធានីភ្នំពេញ និង ខេត្ត ក្រុង ជាកាតព្វកិច្ចរបស់ជនគ្រប់រូបដែលរស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។